**JICA Cambodia Office - JICA カンボジア事務所**

August 29 at 5:03 PM

[សិក្ខាសាលាស្តីអំពីការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា /Workshop for Developing National Guideline of In-Service Training (INSET) for Nurses in Cambodia]

------------------------------

គម្រោងរបស់ JICA សម្រាប់ពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (The Strings) បានរៀបចំសិក្ខាសាលាលើកទីមួយនៅខេត្តកំពត រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៦ ខែសីហា ដើម្បីបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកក្នុងប្រទេសកម្ពុជា។ គម្រោងនឹងបន្តរៀបចំសិក្ខាសាលាចំនួន៣លើក នៅក្នុងខែសីហា កញ្ញា និងតុលា ឆ្នាំ ២០២២នេះ។ សិក្ខាកាមដែលចូលរួមគឺអញ្ជើញមកពីក្រុមការងារបច្ចេកទេស និងគណៈកម្មការគ្រប់គ្រងរបស់គម្រោង រួមមានសមាជិកមកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល មន្ទីរពេទ្យជាតិ (មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យកុមារជាតិ) គណៈគិលានុបដ្ឋាកកម្ពុជា និងសមាគមគិលានុបដ្ឋាកកម្ពុជា។ ក្នុងអំឡុងពេលសិក្ខាសាលា សមាជិករបស់ក្រុមការងារបច្ចេកទេសបានធ្វើការពិភាក្សាយ៉ាងសកម្មទៅលើសេចក្តីសង្ខេបនៃគោលការណ៍ណែនាំថ្នាក់ជាតិនេះ។

យើងខ្ញុំរំពឹងថាសមត្ថភាពរបស់គិលានុបដ្ឋាកនឹងត្រូវបានពង្រឹងបន្ថែមដោយការបង្កើតនូវប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារតាមរយៈការអភិវឌ្ឍគោលការណ៍ណែនាំថ្នាក់ជាតិនេះ ដែលសង្ឃឹមថានឹងអាចបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ២០២២។

អត្ថបទ៖ អ៊ឹង សុដាវី ផ្នែកសុខាភិបាល ការិយាល័យចៃកាប្រចាំប្រទេសកម្ពុជា និង ក្រុមការងារគម្រោង #stringsproject

JICA Project for Strengthening In-Service Training System in Cambodia (The Strings) conducted the first workshop at Kampot province for 3 days from 24th to 26th August with the purpose of developing the national guideline of In-service training for nurses in Cambodia. The project holds a series of workshops in August, September and October this year.

Participants from the technical working group and the steering committee, which consist of members from Human Resource Development Department (HRDD), Hospital Service Department (HSD) of MoH, National Hospitals (Calmette, Khmer-Soviet Friendship, and National Pediatric), Cambodian Council of Nurses (CCN) and Cambodia Association of Nurses (CAN), enthusiastically and actively discussed the outline of the guideline during the workshop.

We expect to improve competency of nurses by establishing in-service training system through the development of guideline, which is expected to finalize within this year.

Creditor: Oeng Sodavy, Health Sector, JICA Cambodia Office, and Project team #StringsProject











